ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះវិហារ

សំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៤
ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០
សំណុំរឿងជំនុំជម្រះលេខ ២២៨
ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១
សាលក្រមព្រហ្មទណ្ឌ
លេខ ៤៥ (ច)
ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះវិហារ

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក ដោយមានសមាសភាព៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ
លោក ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៥៤ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] ខឹម ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រះវិហារ ទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] សួត (រស់) ម្តាយឈ្មោះ [redacted] នាង (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ខេន មានកូនចំនួន ០៣នាក់ ទោសពីមុនគ្មាន ជានីតិជន។ (ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ កាលពីអំឡុងខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៧ កថាខណ្ឌ១ ចំណុច៦ នៃច្បាប់ស្តីពីព្រៃឈើ។

មាន**លោក** [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ



Scanned with CamScanner

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១០១៩ ដ.ស.ព ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាដំណោះស្រាយលេខ ២២១៩ ព្រ/ទ/២១ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦២៧/២០២១ ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាសម្រេចដាក់រឿងទៅជំនុំជម្រះលេខ ៦៤៧/២០២១ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

## អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីអំឡុងខែកក្កដា ឆ្នាំ២០២០ នៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ឈ្មោះ [redacted] ខឹម បានចូលទៅកាប់រានដីព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ នៅក្នុងដីព្រៃរបស់សហគមន៍ព្រៃឈើកោះកេរ្តិ៍រីកចំរើន អស់ទំហំ ២,២១ហិកតា ដើម្បីយកធ្វើជាកម្មសិទ្ធិ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ខឹម បានឆ្លើយនាពេលសវនាការថា ខ្លួនបានកាប់ព្រៃលើដីស្រែ។ ចំពោះដីស្រែនេះ ឪពុកខ្លួនចែកឲ្យ។ លើដីនេះ ពុំមានដើមឈើធំៗឡើយ។ វាលស្មៅធម្មតា។ ខ្លួនកាប់ព្រៃយកដី ដើម្បីដាំដំណាំ ព្រោះខ្លួនមានជីវភាពខ្វះខាត។ ខ្លួនកាប់ព្រៃយកដីនេះ ពុំមានការអនុញ្ញាតពីអាជ្ញាធរឡើយ។ ប៉ុន្តែក្រោយពេលកើតហេតុ ខ្លួនបានធ្វើលិខិតកាន់កាប់ទៅលើដីស្រែនេះ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០។ ខ្លួនទទួលស្គាល់ថា ពិតជាជួលត្រាក់ទ័រឈូសឆាយដីព្រៃប្រាកដមែន ដោយដីនេះ ខ្លួនបានកាន់កាប់តាំងពីឆ្នាំ២០០២។ ពេលខ្លួនកាប់ឆ្ការព្រៃយកដីនេះ ពុំមានអាជ្ញាធរមកហាមឃាត់ទេ។ ខ្លួនកាប់ឆ្ការតាមអ្នកកាប់ឆ្ការក្បែរដីខ្លួនដែរ។ ខ្លួនដឹងថា ជាដីកម្មសិទ្ធិរបស់រដ្ឋ។ ខ្លួនបានដឹងហើយ ប៉ុន្តែខ្លួននៅតែបំពានទៀត។ ចំពោះដីនេះ ប្រសិនបើអាជ្ញាធររដ្ឋយកវិញ ខ្លួនឯកភាពប្រគល់ឲ្យវិញ។ បច្ចុប្បន្ននេះ ខ្លួននៅតែបន្តកាន់កាប់លើដីនេះដដែល ដោយអាស្រ័យលើដីនេះ។ ប៉ុន្តែក្រោយកាប់ឆ្ការរួច អាជ្ញាធរបានចេញប័ណ្ណឲ្យខ្លួនកាន់កាប់។ ក្នុងករណីរដ្ឋត្រូវការដីនេះវិញ ខ្លួនសុខចិត្តប្រគល់ឲ្យរដ្ឋវិញ ដោយមិនមានការប្រកែកឡើយ។ ខ្លួនមានកូន០៤នាក់ ក្នុងបន្ទុកគ្រួសារ។ ខ្លួនជាមេគ្រួសារទទួលបន្ទុកគ្រួសារទាំងមូល។ កំរិតវប្បធម៌ខ្លួនរៀនត្រឹមថ្នាក់ទី២។ ខ្លួនមិនមែនជាជនជាតិភាគតិចឡើយ ខ្លួនជាជនជាតិខ្មែរ។ ពេលខ្លួនកាប់ឆ្ការឈូសឆាយ ពុំមានអាជ្ញាធរហាមឃាត់ឡើយ។ អ្នកប្តឹងខ្លួន គឺសហគមន៍។ លើដីនេះ ឪពុកខ្លួនចែកឲ្យនៅឆ្នាំ២០០២។ ដីទំហំ ប្រហែល ៣ហិកតា។ ចាប់តាំងពីឆ្នាំ២០០២ មកដល់ពេលនេះ ខ្លួនដាំស្រូវរហូតមក។ ថ្លៃឈ្នួលត្រាក់ទ័រ ក្នុង ០១ ហិកតា ចំនួន១.២០០.០០០រៀល (មួយលានម្ភៃម៉ឺនរៀល)។



Scanned with CamScanner

-លោក [redacted] វិស្សិត នាយផ្នែករដ្ឋបាលព្រៃឈើត្បែងមានជ័យ បានឆ្លើយបំភ្លឺនាពេលសវនាការថា នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ០៩ និង១០នាទី មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៃផ្នែករដ្ឋបាលព្រៃឈើត្បែងមានជ័យ និងសង្កាត់រដ្ឋបាលព្រៃឈើគូលែន បានទទួលពាក្យបណ្តឹងពីគណៈកម្មការសហគមន៍កោះកេរ្តិ៍រីកចំរើន ប្តឹងឈ្មោះ [redacted] ខឹម ភេទប្រុស អាយុ ៤០ឆ្នាំ មានទីលំនៅភូមិព្យរជ្រូក ឃុំគូលែនជើង ស្រុកគូលែន ខេត្តព្រះវិហារ ពីបទ **កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃក្នុងសហគមន៍ព្រៃឈើកោះកេរ្តិ៍រីកចំរើន** ស្ថិតនៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ទំហំផ្ទៃដីចំនួន ២,២១ហិកតា។ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ១០ និង ៤០នាទី នៅស្នាក់ការសង្កាត់រដ្ឋបាលព្រៃឈើគូលែន បានធ្វើការប្រជុំ ដោះស្រាយបណ្តឹងរបស់គណៈកម្មការសហគមន៍ព្រៃឈើ កោះកេរ្តិ៍ ដែលចោទឈ្មោះ [redacted] ខឹម បានចូលរុករានភ្ជួរសម្អាតដីព្រៃសហគមន៍ ដើម្បីដាំដំណាំ ក្នុងអង្គប្រជុំ លោក [redacted] ប៉ុណ្ណារិទ្ធ នាយរងផ្នែករដ្ឋបាលព្រៃឈើត្បែងមានជ័យ បានពន្យល់ អប់រំច្បាប់ស្តីពីព្រៃឈើ ហើយក្រោយពីការអប់រំ សុខចិត្តចាកចេញ និងប្រគល់ដីដែលបានកាប់រានថ្មី មកឲ្យគណកម្មការសហគមន៍ព្រៃឈើកោះកេរ្តិ៍រីកចំរើនគ្រប់គ្រងវិញ ទើបរួចផុតពីការចោទប្រកាន់ទោស បន្ទាប់មកឈ្មោះ [redacted] ខឹម បានបំភ្លឺថា ខ្លួនពិតជាបានចូលឈូសឆាយ ភ្ជួរសម្អាតដីព្រៃនៅក្នុងសហគមន៍ព្រៃឈើកោះកេរ្តិ៍រីកចំរើន ដើម្បីដាំដំណាំស្រូវចំនួន ០២ហិកតា ដោយគ្មានលិខិតអនុញ្ញាត និងគ្មានលិខិតកាន់កាប់ឡើយ។ ចំពោះដីនៅដែលនៅក្បែរគាត់នោះ ពួកគាត់បានប្រគល់ឲ្យសហគមន៍វិញហើយ នៅឡើយតែឈ្មោះ [redacted] ខឹម ទេ មិនព្រមប្រគល់ឲ្យសហមគមន៍ ទើបរដ្ឋបាលព្រៃឈើកសាងសំណុំរឿងបញ្ជូនមកកាន់តុលាការ។

-ក្រឡាបញ្ជីអានសលាកប័ត្រទោសទណ្ឌ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់ផ្នែករដ្ឋបាលព្រៃឈើត្បែងមានជ័យ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ស្នើសុំរក្សាបទចោទប្រកាន់នៅដដែល និងស្នើសុំឲ្យតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនសារភាពនូវទោសកំហុស ក្នុងករណីអាជ្ញាធរត្រូវការ កូនក្តីខ្លួនសុខចិត្តប្រគល់ឲ្យវិញ កូនក្តីខ្លួនមានកំរិតវប្បធម៌ទាប ពុំយល់ដឹងច្រើន កូនក្តីខ្លួនកាប់ឆ្ការព្រៃយកដីតាមគេឯងតែប៉ុណ្ណោះ កូនក្តីខ្លួនមេគ្រួសារមានទំនួលខុសត្រូវច្រើន ខ្លួនមេធាវីការពារស្នើសុំឲ្យតុលាការមេត្តាពិនិត្យពិចារណាបន្ធូរបន្ថយទោស និងឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ។

-សម្តីចុងក្រោយរបស់ជនជាប់ចោទ ស្នើសុំឲ្យតុលាការចុះពិនិត្យមើលទៅលើដីជាក់ស្តែង និងស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោស។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការ

ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌



Scanned with CamScanner

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាដែលមានក្នុងសំណុំរឿង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះវិហារ យល់ឃើញថា

១.តុលាការជំនុំជម្រះទទួលបានបណ្តឹងតាមដីកាដំណោះស្រាយលេខ ២២១៤ ព្រ/ទ ២១ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ខឹម ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ (មានសាវតាជាតិខាងលើ) មកតុលាការដើម្បីជំនុំជម្រះ ពីបទ **កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត** ប្រព្រឹត្តនៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ កាលពីអំឡុងខែកក្កដា ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៩៧ កថាខណ្ឌ១ ចំណុច៦** នៃច្បាប់ស្តីពីព្រៃឈើ។

២.នាពេលសវនាការ តាមចម្លើយសារភាពរបស់ជនជាប់ចោទ តាមចម្លើយបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងការពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង បង្ហាញឲ្យឃើញថាជនជាប់ចោទ ពិតជាបានធ្វើសកម្មភាព **កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត** ទៅលើដីទំហំប្រមាណ ២,២១ហិកតា មានទីតាំងស្ថិតនៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ កាលពីអំឡុងខែកក្កដា ឆ្នាំ២០២០ ប្រាកដមែន ហេតុដូច្នេះតុលាការមានមូលដ្ឋានគ្រប់គ្រាន់សម្រេចតាមច្បាប់បាន តាមបញ្ញត្តិមាត្រា **៩៧ កថាខណ្ឌ១ ចំណុច៦** នៃច្បាប់ស្តីពីព្រៃឈើ។

៣.តំណាងអយ្យការ បានស្នើសុំរក្សាបទចោទប្រកាន់នៅដដែល និងស្នើសុំឲ្យតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់ ហេតុដូច្នេះគប្បីតុលាការពិចារណា។

៤.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ដែលត្រូវបានច្បាប់ការពារតាមបញ្ញត្តិមាត្រា **៩៧ កថាខណ្ឌ១ ចំណុច៦** នៃច្បាប់ស្តីពីព្រៃឈើ។

៥.ជនជាប់ចោទជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងខុសត្រូវពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន និងមិនមានភស្តុតាងណាមួយ បញ្ជាក់ពីការមានវិបល្លាស ស្មារតីរបស់ជនជាប់ចោទ ដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះមុខច្បាប់។

៦.មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ខឹម ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ ពីបទ **កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត** ប្រព្រឹត្តនៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ កាលពីអំឡុងខែកក្កដា ឆ្នាំ



Scanned with CamScanner

២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩៧ កថាខណ្ឌ១ ចំណុច៦ នៃច្បាប់ស្តីពីព្រៃឈើ។

៧.ជនជាប់ចោទបានឆ្លើយសារភាពនូវទោសកំហុសរបស់ខ្លួន ហើយទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង គប្បីតុលាការពិចារណាអំពីលក្ខខណ្ឌដែលនាំឲ្យមានការព្យួរទោសទៅលើជនជាប់ចោទបាន តាមបញ្ញត្តិមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសាលាដំបូងខេត្តព្រះវិហារ**

**វិនិច្ឆ័យសេចក្តី**

ផ្តន្ទាទោសលើឈ្មោះ [redacted] ខឹម ភេទប្រុស កើតឆ្នាំ១៩៨០ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ (ប្រាំ) ឆ្នាំ តែទោសនេះត្រូវអនុវត្តព្យួរ ពីបទ កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃដោយគ្មានលិខិតអនុញ្ញាត បទល្មើសប្រព្រឹត្តនៅភូមិកោះកេរ្តិ៍ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ កាលពីអំឡុងខែកក្កដា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៩៧ កថាខណ្ឌ១ ចំណុច៦ នៃច្បាប់ស្តីពីព្រៃឈើ។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ខឹម។

*បើកសិទ្ធិឲ្យភាគីប្តឹងឧទ្ធរណ៍តាមច្បាប់។*

ថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ព្រះវិហារ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

| **ក្រឡាបញ្ជីសវនាការ** | **ក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រុមប្រឹក្សាជំនុំជម្រះ** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១០កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ព្រះវិហារ, ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner